ហួត សេងគៀ

# ឱ្យគេដេកទៅ

## កុំព្យាយាមដាស់ មនុស្សដែលចង់ដេក

**Samanh** EBooks

# ឱ្យគេដេកទៅ

កុំព្យាយាមដាស់ មនុស្សដែលចង់ដេក

# សៀវភៅផ្សេងទៀត

៤ឆ្នាំ

ចរិតឆ្កែ

អាល់ប៊ុមគំនិត ភាគពីរ

ជម្រើសទីពីរ

រើសមកទុកវិញ

រៀនតាមឆាវឆាវ

ជីវិតយើងខ្លីពេក

ទស្សនៈខ្ញុំគេ

រក្សាសិទ្ធិគ្រប់យ៉ាងដោយអ្នកនិពន្ធ ហួត សេងគៀ

ឆ្នាំ 2017

# មាតិកា

**ទំព័រដើម**

7
**ធ្វើការពេលព្រឹក**

9
**សិទ្ធិរបស់គេ**

11
**បើយើងអាចភ្ញាក់ម្នាក់ឯង គឺគ្រប់គ្រាន់ហើយ**

14
**ប្រយ័ត្នគេខឹង**

18
**មិនបាច់ខ្វល់ពីអ្នកណាច្រើនទេ**

20
**ទាល់តែដេកលក់ទើបស្រួលមើរតាមគេ**

24

បើយើងមិនមែនជាអ្នកនយោបាយ កុំចង់អូសទាញ
គេ

27
ជួយដោយគ្មានគេសុំ

30
គតដល់នយោបាយ និងសាសនាផង

32
ដឹងថាហេតុអីគេមិនចង់ឱ្យយើងរៀនច្រើនពេកទេ?
35

# ទំព័រដើម

ខ្ញុំកំពុងជាប់គាំងជាមួយសៀវភៅ ទស្សនៈខ្ញុំគេ របស់ខ្ញុំ ដោយបញ្ហាផ្ទាល់ខ្លួន ហេតុនេះខ្ញុំមិនដឹងត្រូវសរសេរអ្វីទេ។ ខ្ញុំក៏សរសេរអាក្រក់ពីអ្នកនយោបាយ និងសាសនា ដើម្បីឱ្យផេករបស់ខ្ញុំមានអ្វីថ្មីខ្លះ។ ខ្ញុំសរសេរដូចរាល់ដង ដូចកាលពីពីរបីឆ្នាំមុន ដែលខ្ញុំមិនចូលចិត្តអ្នកនយោបាយ និងសាសនា។ ប្រហែលជាពេលនេះ ការមិនចូលចិត្តរបស់ខ្ញុំរីកធំ ហើយការប្រើពាក្យរបស់ខ្ញុំ ក៏ធ្ងន់ជាងមុនដែរ។

មានកញ្ជះនយោបាយដែលមិនធ្លាប់បានលុយពីនយោបាយពីរបីនាក់ ចូលមកបញ្ចេញកំហឹងដាក់ខ្ញុំ។ គេថាខ្ញុំមានចិត្តអាត្មានិយម និងមិនចេះស្វែងយល់ពីនយោបាយ និងសរសេរច្រើនទៀត តែខ្ញុំមិនបានអាន ហើយក៏ចុចលុបចោលទៅ។ ពាក្យរបស់ពួកគេនេះ ធ្វើឱ្យខ្ញុំនឹកឃើញថា ចុងអាទិត្យនេះខ្ញុំអត់មានទៅណាទេ ហេតុនេះខ្ញុំគួរតែសរសេរសៀវភៅខ្លីមួយនិយាយពីគោលបំណង និងការមិនខ្វល់របស់ខ្ញុំចំពោះមនុស្សប្រភេទនេះ។

វាជារឿងមួយគួរឱ្យភ្ញាក់ផ្អើលមែនទែន ដែលពាក្យអត់ប្រយោជន៍ និងសំណួរបែបអត់ខួររបស់ពួកគេ ជួយឱ្យខ្ញុំអាចជំនះការជាប់គាំងរបស់ខ្ញុំបាន ហើយបញ្ចប់បានកូនសៀវភៅថ្មីមួយទៀត។ អ្នកនិពន្ធត្រូវចេះរកវិធីនៅពេលជួយ writer block ព្រោះបើមិនដូច្នោះទេ អ្វីក៏សរសេរលេងចេញដែរ។ ខ្ញុំអត់បានរកទេ គឺវារត់មកខ្ញុំដោយខ្លួនឯង។ ខ្ញុំបានអរគុណពួកគេ ដោយ block ពួកគេចោលពីលើផេករបស់ខ្ញុំ។ ខ្ញុំពិតជាមិនជឿខ្លួនឯងសោះដែលអាចទាញ ប្រយោជន៍ពីកញ្ជះនយោបាយទាំងនោះបាន។

នៅពេលនេះ ខ្ញុំត្រូវប្ដូរពាក្យហើយ។ ពីមុន ខ្ញុំនិយាយថា “កញ្ចុះនយោបាយមានប្រយោជន៍សម្រាប់តែអ្នកនយោបាយប៉ុណ្ណោះ” តែឥលូវខ្ញុំត្រូវប្ដូរមកជា “កញ្ចុះនយោបាយ ក៏អាចជួយអ្នកនិពន្ធឱ្យមានអ្វីសរសេរដែរ”។

ខ្ញុំសង្ឃឹមថា អ្នកទាំងអស់គ្នាដែលអានសៀវភៅនេះ នឹងរីករាយក្នុងការអាន ហើយអានចប់ក្នុងពេលខ្លីបំផុត។ សៀវភៅខ្លី មិនបាច់ប្រើពេលយូរទេ។ ខ្ញុំមិនសង្ឃឹមថា អ្នកទាំងអស់គ្នាអាចទទួលបានផលអ្វីជំដុំពីសៀវភៅនេះទេ ព្រោះនេះជាសៀវភៅសម្រាប់អានលេង។ បើសិនជាសៀវភៅនេះអាចជួយអ្វីដល់អ្នកទាំងអស់គ្នាបាន ខ្ញុំក៏សូមចូលរួមអបអរផង តែសូមកុំគិតថាខ្ញុំមានបំណងជួយអ្វីឱ្យសោះ។

ហួត សេងគៀ

# ១

# ធ្វើការពេលព្រឹក

មិនមែនមនុស្សគ្រប់គ្នាសុទ្ធតែចូលចិត្តធ្វើការពេលព្រឹកនោះទេ តែពេលខ្លះយើងក៏គ្មានជម្រើសដែរ បើក្រុមហ៊ុនដែលយើងធ្វើការ គ្មានម៉ោងសម្រាប់យើងរើស។ ក្រុមហ៊ុនខ្លះនៅប្រកាន់ជំនឿថា បុគ្គលិកនឹងមានភាពស្មុះស្មានៅពេលព្រឹក។ ក្រុមហ៊ុននៅតែចាត់ទុកបុគ្គលិកជាមនុស្សប្រភេទដូចគ្នាដដែល។

រាល់ព្រឹក ខ្ញុំដាក់ម៉ោងរោទិ៍ពីរបីដង តែនៅងើបមិនរួច ព្រោះខ្ញុំច្រើនតែចូលដេកយប់ជ្រៅ។ ម៉ាក់ខ្ញុំ ឡើងមកដាស់ខ្ញុំរាល់ព្រឹក ដើម្បីកុំឱ្យទៅធ្វើការយឺត។ ទោះបីជាដាស់ ក៏ខ្ញុំនៅតែទៅយឺត។ ខ្ញុំក្លាយជាបុគ្គលិកទៅធ្វើការយឺតជាងគេប្រចាំក្រុម។ បើពេលណាខ្ញុំទៅលឿនម្ដង គេនឹងមានពាក្យមកថាឱ្យខ្ញុំហើយ តែខ្ញុំមិនប្រកាន់ទេ ព្រោះធ្វើការក្នុងក្រុមជាមួយគ្នា។

ប៉ាខ្ញុំ មិនដូចម៉ាក់ខ្ញុំទេ។ បើគាត់ឡើងមកហៅខ្ញុំម្ដងហើយ តែខ្ញុំមិនងើបគាត់ក៏មិនឡើងមកហៅម្ដងទៀតដែរ។ ពេលណាដែលម៉ាក់ខ្ញុំមិននៅផ្ទះហើយប៉ាខ្ញុំទទួលភារកិច្ចដាស់ខ្ញុំ ខ្ញុំច្បាស់ជាទៅធ្វើការយឺត១ម៉ោង ឬត្រូវយកលេសសុំច្បាប់អត់ទៅធ្វើការតែម្ដង។ ប៉ាខ្ញុំនិយាយថា “បើវាចង់ដេកឱ្យវាដេកឱ្យឆ្អែតទៅ” ហើយថ្ងៃនេះ ខ្ញុំនឹងយកពាក្យរបស់គាត់មកសរសេរជាកូនសៀវភៅនេះ។

ខ្ញុំនឹងយកការដេកមិនចង់ភ្ញាក់របស់ខ្ញុំ មកប្រៀបធៀបនឹងមនុស្សមួយចំនួនដែលខ្ញុំជួបនៅលើអ៊ីនធឺណេត។ ការប្រៀបធៀបនេះ គ្មានគោលបំណងអីក្រៅពីឱ្យអ្នកអានបានគិតលេងទេ។ ខ្ញុំមិនគិតថា អ្នកទាំងអស់គ្នាដែលសម្រេចចិត្តថាអានសៀវភៅរបស់ខ្ញុំដោយរំពឹងចង់បានទ្រឹស្តីអស្ចារ្យ ឬក្បួនរកស៊ីនោះទេ។ ខ្ញុំសរសេរសៀវភៅបែបណា អ្នកដែលធ្លាប់អានស្នាដៃរបស់ខ្ញុំដឹងច្បាស់ហើយ។ អ្នកដែលមិនធ្លាប់អាន ក៏បានដឹងនៅពេលនេះដែរ។

# ២

# សិទ្ធិរបស់គេ

មនុស្ស ជាប្រភេទសត្វដែលអស្ចារ្យជាងសត្វដទៃ។ អ្វីដែលធ្វើឱ្យយើងអស្ចារ្យ គឺការបង្កើតថ្មីរបស់យើង។ យើងបង្កើតអ្វីជាច្រើន រួមមានទាំងរបស់ល្អ និងរបស់មិនបានការ។ ក្នុងនោះដែរ យើងបានបង្កើតសិទ្ធិទៅឱ្យមនុស្សគ្រប់គ្នា (មិនមែនគ្រប់គ្នាទេ ព្រោះជនជាតិខ្លះមិនទាន់មានសិទ្ធិពេញលេញនៅឡើយទេ) ដើម្បីអាចរស់នៅដោយស្មើភាពគ្នាបាន។

គេមានសិទ្ធិរបស់គេ ដែលអាចជ្រើសរើសរបៀបរស់នៅបានតាមចិត្ត។ ខ្ញុំរើសការរស់នៅរបស់ខ្ញុំ ដោយបដិសេធមនុស្សដែលចង់មកធ្វើជាអ្នកដឹកនាំទាំងអស់។ ពួកគេនៅតែធ្វើជាអ្នកដឹកនាំដដែលទេ តែខ្ញុំមិនទទួលស្គាល់អ្នកណាមកត្រួតត្រាជីវិតខ្ញុំទេ។ ខ្ញុំមិនស្លាប់ដើម្បីមហិច្ឆតាអ្នកដទៃ ហើយក៏មិនចំណាយពេលការពារគំនិត ឬគោលការណ៍របស់អ្នកណាទាំងអស់។

ខ្ញុំគាំទ្រសេរីភាពដែលខ្ញុំយល់ថា ល្អសម្រាប់មនុស្ស។ ការយកអ្នកនយោបាយ ឬសាសនា មកគ្រប់សង្កត់លើជីវិត និងការយល់ឃើញរបស់យើង ជាការបោះបោលសេរីភាពផ្ទាល់ខ្លួន។ បើសូម្បីតែសេរីភាពក៏មិនយើងចង់បានផង តើយើងរស់នៅមានន័យអី? ជីវិតត្រូវការសេរីភាព ទោះបីមិនអាចទៅធ្វើអ្វីគ្រប់យ៉ាងបានមែន តែរឿងសំខាន់ក្នុងជីវិត គឺយើងជាអ្នកសម្រេច។

ពួកគេ មានសិទ្ធិដូចខ្ញុំដែរ តែខុសគ្នាត្រង់អ្វីដែលពួកគេរើស។ គេផ្ញើវាសនាលើអ្នកនយោបាយ និងជឿលើសាសនា។ គេគិតថា បើគេគាំទ្រមនុស្សទាំងនោះ ពួកគេនឹងបានអ្វីដែលខ្លួនចង់បាន។ ជំនឿរបស់ពួកគេ បានប្រែក្លាយខួរក្បាលក្លាយទៅជាខួរចៀម ដែលចូលចិត្តធ្វើអ្វីជាហ្វូង និងមិនចេះមានគំនិតផ្ទាល់ខ្លួន។

និយាយដល់រឿងចៀមនេះ ខ្ញុំមានសំណួរមួយឱ្យគិត។ ខាងគណបក្សប្រឆាំង ចូលចិត្តជៀមដាមគណបក្សកាន់អំណាចថា “ក្បាលយួន ខ្លួនខ្មែរ” ដោយគិតថា ពាក្យនេះសំដៅលើបុគ្គលក្បត់ជាតិ។ នៅមានពាក្យមួយទៀត ដែលអាក្រក់មិនចាញ់ពាក្យនេះប៉ុន្មានទេ គឺ “ក្បាលចៀម ខ្លួនជាកូនអុក”។ ពាក្យនេះសំដៅលើកូនអុកនយោបាយទាំងអស់ដែលស្ម័គ្រចិត្ត និងកាយបម្រើអ្នកនយោបាយ និងរីករាយពេលឃើញគេបានកាន់អំណាច។ ក្បាលយួន ខ្លួនខ្មែរ អាចឆ្លាតទៅតាមពូជយួន តែក្បាលចៀមវិញ ទោះបីខ្លួនជាជនជាតិអីក៏ដោយ ក៏ជៀសមិនផុតពីពាក្យថា ភ្លើ ដែរ។

ខ្ញុំប្រាប់តាមត្រង់ចុះ ខ្ញុំមិនដែលសប្បាយចិត្តនឹងឃើញអ្នកនយោបាយណាឡើងកាន់អំណាចទេ ព្រោះខ្ញុំដឹងថា អំណាច នឹងពង្វក់ចិត្តរបស់ពួកគេនៅពេលណាមួយ។ អ្នកនយោបាយ ក៏ដូចយើងដែរ ពេលបានអំណាចយូរទៅ គង់តែក្លាយជាអាក្រក់ ហើយមកធ្វើស៊ីអ្នកគាំទ្រវិញមិនខាន។ កុំទាន់វាយតម្លៃអ្នកនយោបាយនៅពេលគេមិនទាន់បានអំណាចពេញលេញ។ គេស្លូត ព្រោះមហិច្ឆតាគេមិនទាន់សម្រេច ហើយគេនឹងធ្វើកាចដាក់យើងពេលយើងលែងមានតម្លៃឱ្យគេ។

ខ្ញុំដូចជាសរសេរវែងឆ្ងាយពេកហើយ។ សៀវភៅនេះ ជាសៀវភៅខ្លី ដូច្នេះការពន្យល់មិនអាចក្បោះក្បាយបានទេ។ នេះមិនមែនជាបញ្ហាសម្រាប់អ្នកអានទេ ព្រោះអ្នកអានចេះគិត និងចេះពន្យល់ខ្លួនឯងឱ្យយល់ច្បាស់

ជាងអ្នកនិពន្ធអាចពន្យល់បានទៀត។ យ៉ាប់តែអ្នកអានដែលមិនចេះគិត និងដេកចាំគេញ៉ុកគំនិតចូលខួរស្រាប់ប៉ុណ្ណោះ។ អ្នកអានប្រភេទនេះ មិនស្គាល់ប្រយោជន៍នៃការអានប៉ុន្មានទេ។ អ្នកអានល្អ ប្រើភ្នែកដើម្បីពិនិត្យអក្សរកុំឱ្យអានខុស និងប្រើខួរក្បាលគិតរាល់អ្វីដែលគេអាន។ ការអាន ជាផ្នែកមួយនៃការគិត។

ដូចខ្ញុំបញ្ជាក់រួចហើយ ពួកគេមានសិទ្ធិរើសយកដេកបន្ត ឬភ្ញាក់ដើម្បីធ្វើការ។ បើគេជ្រើសយកភ្ញាក់ ពួកគេនឹងត្រូវជួបរឿងច្រើនដើម្បីរៀន និងស្គាល់មុខមាត់ពិតរបស់អ្នកដទៃដែលត្រូវដកខ្លួនចេញ។ តែបើគេជ្រើសរើសយកដេកបន្តទៀត ក៏មិនមែនជាបញ្ហារបស់ខ្ញុំដែរ។ បើខ្ញុំបំពានសិទ្ធិគេ បានន័យថា ខ្ញុំចង់រករឿងមកដាក់ខ្លួន។

មនុស្សដែលងប់នឹងនយោបាយ មិនទទួលយកគំនិតដែលប្រឆាំងនឹងអ្នកនយោបាយនោះទេ។ គេនឹងខឹងខ្លាំង បើខ្ញុំនិយាយប៉ះពាល់ដល់អ្នកនយោបាយដែលគេស្រលាញ់ និងដេកសង្ឃឹមរាល់ថ្ងៃ។ ខ្ញុំមិនភ្លើដល់ថ្នាក់ យករឿងមកឱ្យខ្លួនឯងឈឺក្បាលទេ ថាមិនត្រូវ គេអាចនឹងមកចាត់ការខ្ញុំផង ក៏ថាបាន។ ឱ្យតែមានពាក្យថា “ងប់” ហើយ អ្វីក៏មិនបាច់បកស្រាយបន្តដែរ។

# ៣

# បើយើងអាចភ្ញាក់ម្នាក់ឯង គឺគ្រប់គ្រាន់ហើយ

តើធ្លាប់លឺពាក្យគេថា “ជួយបានប៉ុណ្ណា ជួយប៉ុណ្ណឹង” ដែរទេ? ពាក្យនេះ មិនមែនជាការខ្ជិលច្រអូសទេ តែជាការតាំងចិត្តជួយពិតប្រាកដ។ បើអង្គុយគិតថា ត្រូវជួយឱ្យអស់គ្នា យើងមិនអាចជួយអ្នកណាបានទាំងអស់។ មនុស្សដែលយើងអាចជួយបានមុនគេ និងសំខាន់ជាងគេ គឺខ្លួនយើង។ យើងជួយខ្លួនឯងបាន គឺគ្រប់គ្រាន់ហើយ ឬអាចនិយាយថា ភារកិច្ចរបស់យើង បានសម្រេចទៀតផង។

ការភ្ញាក់ខ្លួន មិនមែនជារឿងងាយទេ។ អ្នកខ្លះ ទាល់មនុស្សក្នុងគ្រួសារស្លាប់អស់ ទើបភ្ញាក់ខ្លួន។ ខ្លះទៀត ដល់តែពេលជិតស្លាប់ ទើបភ្ញាក់ខ្លួនថាពីមុនសម្រេចចិត្តខុស។ ការភ្ញាក់ខ្លួន មិនមែនកើតឡើងបានដោយសារអានសំណេរមួយអត្ថបទ ឬការផុស status ខ្លីៗនៅលើហ្វេសប៊ុកដែរ។ វាកើតឡើងពីមនុស្សដែលមានចិត្តចង់ភ្ញាក់ខ្លួន និងជឿថា ខ្លួនឯងមិនទាន់ភ្ញាក់។

អ្នកទាំងអស់គ្នាធ្លាប់សម្គាល់ដែរទេ ពេលខ្លះយើងកំពុងដេកសោះ តែមានអារម្មណ៍ថាខ្លួនឯងភ្ញាក់រួចហើយ? វាដូចគ្នានឹងការភ្ញាក់ខ្លួនក្នុងជីវិតយើងដែរ។ យើងមានអារម្មណ៍ថា យើងភ្ញាក់ខ្លួនពេលបានជួបនឹងអ្នកនយោបាយថ្មី ឬសាសនាថ្មី ហើយគិតថា “លើកនេ ះអញរកបានចង្កៀនហ្គាសហើយ”

តែតាមពិត យើងនៅដេកសោះ។ ការភ្ញាក់ខ្លួនពិតប្រាកដ គឺ យើងដឹងថា គេគ្មានខ្វល់ពីយើងទេ គេខ្វល់ពីមហិច្ឆតារបស់គេប៉ុណ្ណោះ ប៉ុន្តែដោយសារតែមហិច្ឆតារបស់គេត្រូវការមនុស្សដើរតាមច្រើន ទើបគេធ្វើជាខ្វល់នឹងយើងជាបណ្តោះអាសន្នសិន។ ការខ្វល់ និងការធ្វើជាខ្វល់ ជារឿងពីរផ្សេងគ្នា ហើយឱ្យផលខុសគ្នា។

អ្នកដែលជឿលើអ្នកនយោបាយ មិនងាយភ្ញាក់ខ្លួនទេ។ ពួកគេនៅបន្តក្តីសង្ឃឹមជានិច្ច ថាអ្នកនយោបាយនេះមិនបោកគេដូចអ្នកនយោបាយមុនៗ តែក្តីសង្ឃឹមបែបនេះ មិនអាចបានផលទេ។ ខ្ញុំមើលអ្នកនយោបាយ ជាប្រភេទមនុស្សតែមួយ ហើយអ្វីដែលខុសគ្នា គឺវិធីសាស្ត្រដែលពួកគេប្រើដើម្បីទាក់ទាញមនុស្ស និងកម្រិតនៃភាពលោភលន់របស់ពួកគេ។

ការចង់ដឹកនាំគេ ឬអាចហៅម្យ៉ាងទៀតថា ការចង់នៅពីលើក្បាលគេ ជាភាពលោភលន់មួយ ដែលមនុស្សនាំគ្នាឆ្គួតទទួលស្គាល់ថាជារឿងល្អ។ មេដឹកនាំ ជាអ្នកលុបបំបាត់សេរីភាពរបស់យើងគ្រប់គ្នា។ គេមិនលុបម្តងទាំងអស់ទេ តែគេធ្វើម្តងមួយជំហានប្រកបដោយហេតុផលសមទំនងបំផុត ដើម្បីកុំឱ្យយើងភ្ញាក់ខ្លួន។ អ្នកដែលចង់នៅពីលើយើងហើយ ក៏គេមិនចង់ឱ្យយើងភ្ញាក់ខ្លួនដែរ ព្រោះវាពិបាកគ្រប់គ្រង ហើយគេខ្លាចអំណាចដែលគេប្រឹងយកបាន នឹងរង្គោះចេញ។ អ្នកដែលស្រលាញ់អំណាច សុទ្ធតែជាមនុស្សមិនល្អ។

រៀនភ្ញាក់ខ្លួនឱ្យបាន ហើយត្រូវប្រឹងរៀនបន្ថែមទៀត ដោយអានឱ្យបានច្រើន និងសង្កេតមើលសកម្មភាពរបស់អ្នកនយោបាយ។ នៅពេលយើងដកជំនឿគ្រវាត់ចោលហើយ យើងនឹងអាចមើលឃើញច្រើនពីអ្នកនយោបាយដែលយើងធ្លាប់ស្រលាញ់ពីមុន។ យើងអាចនឹងប្រែជាខឹង ឬមិនពេញចិត្តនឹងអ្វីដែលពួកគេធ្វើផង។ កុំអានអ្វីដែលនយោបាយសរសេរក្នុងគោល

បំណងអូសទាញ ព្រោះយើងមិនប្រាកដថាអាចទប់ទល់នឹងកម្លាំងអូសទាញរបស់ពួកគេបានទេ។ ជំនាញពិតប្រាកដរបស់អ្នកនយោបាយ គឺអូសទាញឱ្យគេជឿ ព្រោះបើគេមិនជឿ ក៏ធ្វើនយោបាយមិនចេញដែរ។

សាកគិតទៅមើល បើមនុស្សមួយប្រទេស ឬមួយផ្នែកធំមិនជឿអ្នកនយោបាយ តើអ្នកនយោបាយនៅមានអំណាចដែរទេ? តើគេអាចធ្វើអ្វីបានតាមចិត្តដែរទេ? តើគេអាចប្រើសម្ដីប្រមាថអ្នកដទៃបានទៀតទេ? គឺមិនអាចទេ។ បើគ្មានអ្នកណាដើរតាម តើអាចធ្វើមេដឹកនាំអីកើត? ខ្ញុំគិតថាបែបនេះល្អ តែអ្នកដទៃគិតថាបែបនេះ គ្រោះថ្នាក់ ព្រោះគ្មានអ្នកនយោបាយការពារសុវត្ថិភាពឱ្យ។ វាអាចនឹងគ្រោះថ្នាក់ ព្រោះបើយើងអាចអស់ជំនឿលើអ្នកនយោបាយទាំងស្រុង យើងក៏នៅសល់ជំនឿលើសាសនាមួយទៀត។ សាសនា ក៏ជារបស់គ្រោះថ្នាក់ដូចគ្នា។ បើប្រទេសគ្មានច្បាប់គ្រប់គ្រងលោកសង្ឃ ឬអ្នកដែលតាំងខ្លួនជាគ្រូមន្តអាគម នឹងបោកមនុស្សកាន់តែច្រើន។ គ្រោះថ្នាក់ មិនចេះអស់ទេ នៅក្នុងជីវិតយើង។

ប៉ុន្តែសូមកុំភ័យ អ្វីដែលខ្ញុំលើកឡើងនេះ ជាការចង់បានរបស់ខ្ញុំប៉ុណ្ណោះ ដូច្នេះ វាគ្មានថ្ងៃកើតឡើងបានទេ។ អ្នកផ្សេងទៀត គេនៅតែចង់ដេកលក់ក្រោមឥទ្ធិពលរបស់មនុស្សដែលចង់ធ្វើជាអ្នកដឹកនាំគេដដែល។ ខ្ញុំគ្មានបញ្ហាទេ ទោះបីអ្វីដែលខ្ញុំចង់បាន មិនអាចកើតឡើង តែខ្ញុំក៏មានសេរីភាពមិនតិចដែរ ព្រោះខ្ញុំគ្មានជំពាក់នឹងមន្តស្នេហ៍អ្នកនយោបាយណា។ ខ្ញុំជាប់ចិត្តនឹងលុយរបស់ពួកគេ។ បើគេឱ្យលុយខ្ញុំ ខ្ញុំនឹងយក តែបើឱ្យខ្ញុំស្លាប់ដើម្បីគេ ខ្ញុំនឹងរត់។

ខ្ញុំត្រូវការលុយ ដើម្បីពង្រីកសេរីភាពរបស់ខ្ញុំ តែខ្ញុំមិនត្រូវការអ្នកនយោបាយចូលមកលូកលាន់ក្នុងជីវិតខ្ញុំច្រើនពេកទេ ព្រោះពួកនេះនឹងមកបង្រួមសេរីភាពរបស់ខ្ញុំវិញ។ គេមិនចូលចិត្តអ្នកណាមានសេរីភាពខ្លាំងពេកទេ

ព្រោះសេរីភាពរបស់ប្រជាជន ជាបញ្ហារបស់អំណាចអ្នកនយោបាយ។ បើមួយឡើងធំ មួយទៀតអាចនឹងរួមតូច ហេតុនេះគេមិនលូង់ឱ្យសេរីភាពមកប្រជាជនច្រើនពេកទេ។ គេឱ្យតិចៗ ដើម្បីបានថតដាក់ទូរទស្សន៍ និងដាក់ហ្វេសប៊ុកយក like។

ខ្ញុំគិតថា វាគ្រប់គ្រាន់សម្រាប់ខ្ញុំហើយ ដែលអាចភ្ញាក់ខ្លួនមើលឃើញពីចំណុចអាក្រក់របស់អ្នកមានអំណាច និងអ្នកដែលជិតមានអំណាច។ ដេកលក់ ក៏វាស្រួលដែរ ព្រោះមិនបាច់ខ្វល់នឹងការពិត តែយើងជាមនុស្សនៅដកដង្ហើម នៅផុះអាចម៍ តើចង់ដេករហូតម៉េចនឹងសម? ខ្មោចក្នុងដីប្រណែនយើងងាប់ហើយ បើយើងដេករហូត ហើយមិនរលួយស្អែកដូចពួកគេនោះ។

បើចង់ភ្ញាក់ ភ្ញាក់តែឯងបានហើយ កុំបាច់ទៅដាស់អ្នកណាទាំងអស់។ ជឿខ្ញុំទៅ វាគ្មានបានការស្អីទេ។ មិនបាច់ជឿខ្ញុំក៏បានដែរ សាកដោយខ្លួនឯងទើបភ្លឺភ្នែកជាង។ ត្រូវគេជេរតែប៉ុន្នានដង នឹងអស់អារម្មណ៍ជួយអ្នកណាទាំងអស់។

# ៤

# ប្រយ័ត្នគេខឹង

មនុស្សកំពុងតែដេកលក់ស្រួល ហើយយើងទៅដាស់គេ គេច្បាស់ជាខឹងយើងមិនខាន។ យើងអាចនឹងរំខានការយល់សប្តិអាសអាភាសរបស់គេ ឬអាចកាត់ចង្វាក់គេលួចមើលអ្វីមួយក៏ថាបាន។ ពេលគេដេក កុំដាស់។ ឱ្យគេដេកឱ្យឆ្អែត ហើយយើងទៅធ្វើការរបស់យើង ពេលគេភ្ញាក់មក អ្វីៗនឹងហួសពេល។ ដេកលក់យូរ កាន់តែភ្លើ។

យើងត្រូវដឹងពីមូលហេតុដែលគេមិនចង់ភ្ញាក់ដូចយើងសិន។ គេមិនចង់ភ្ញាក់ ព្រោះបើភ្ញាក់ខ្លួនទៅ នឹងមើលឃើញទំនួលខុសត្រូវ ការអស់សង្ឃឹម និងឧបសគ្គច្រើនពេក ហេតុនេះមានតែជ្រើសយកការដេកលក់ ហើយដាក់ក្តីសង្ឃឹមទៅលើអ្នកដទៃដែលពូកែនិយាយ និងធ្វើកាយវិការវិញ ទើបស្រណុកចិត្តជាង។ ចរិតកំសាករបស់ប្រជាជន គឺជាកាដូពិសេសសម្រាប់អ្នកនយោបាយ។ អ្នកនយោបាយនឹងបង្រៀនយើងឱ្យក្លាហាន តែពេលត្រូវទៅច្បាំងដើម្បីការពារអំណាចរបស់ពួកគេ ឬការពារពួកគេពីសត្រូវដែលមានកម្លាំងខ្លាំងជាងប៉ុណ្ណោះ។ ក្រៅពីនេះ គេនឹងសុំឱ្យយើងរៀនធ្វើជាមនុស្សកំសាក កុំចង់ដឹងចង់លឺច្រើនពេក។ គេចង់ឱ្យយើងដេកលក់។

បើយើងដឹងហេតុផលនេះហើយ ពេលឃើញគេដេកលក់ កុំដាស់គេ។ ទុកឱ្យគេសប្បាយក្នុងការយល់សប្តិរបស់គេទៅ ហើយយើងចំណាយពេលមករស់នៅក្នុងការពិតវិញ។ ការពិតមិនល្អដូចយល់សប្តិទេ តែយើងបាន

ដកខ្លួនចេញពីពិភពកំសាក។ កុំធ្វើឱ្យមនុស្សបែបនេះខឹង។ មនុស្សកំសាក សាហាវណាស់។ ធ្វើជាមើលមិនឃើញ ល្អជាង។

# ៥

# មិនចាំបាច់ខ្វល់ពីអ្នកណាច្រើនទេ

យើងមិនអាចរស់នៅដោយមិនខ្វល់ពីអ្នកណាសោះបានទេ តែយើងអាចរើសមនុស្សដែលយើងត្រូវខ្វល់បាន។ មនុស្សដែលយើងត្រូវខ្វល់នេះហើយដែលត្រូវដាស់គេម្ដងបន្តិច។ កុំដាស់បង្ខំ ព្រោះវាអាចធ្វើឱ្យទំនាក់ទំនងយើងជួបបញ្ហា។ យើងអាចខ្វល់ពីគ្រួសារយើង មិត្តភក្តិជិតដិត ឬគូស្នេហ៍របស់យើងបាន ព្រោះពួកគេទើបជាមនុស្សសំខាន់។

អ្នកផ្សេងទៀត ឱ្យគេដេកតាមដំណើរទៅ ព្រោះពួកគេក៏មានមនុស្សដែលខ្វល់ពីពួកគេដែរ។ កុំដណ្ដើមគ្នាខ្វល់ ហើយកុំខ្វល់នឹងមនុស្សដែលមិនពាក់ព័ន្ធនឹងយើង។ ក្នុងនាមខ្ញុំជាអ្នកនិពន្ធ ខ្ញុំអាចនិយាយថា ខ្ញុំខ្វល់ពីអ្នកអានរបស់ខ្ញុំក៏បានដែរ ព្រោះគោលបំណងនៃសៀវភៅរបស់ខ្ញុំទាំងអស់គឺទុកពេលឱ្យអ្នកអានគិត។ តែបើឱ្យខ្ញុំទៅដាស់អ្នកអានទាំងអស់ឱ្យភ្ញាក់ហើយគិតដូចខ្ញុំ ខ្ញុំមិនធ្វើទេ ព្រោះនេះមិនមែនភារកិច្ចរបស់អ្នកនិពន្ធ។

អ្នកដែលអានអ្វីដែលខ្ញុំសរសេរអាក្រក់ពីអ្នកនយោបាយ ឬសាសនា អាចនឹងគិតថា ខ្ញុំខ្វល់ពីពួកគេ ទើបពួកគេចំណាយពេលមកសរសេរ comment មកឱ្យខ្ញុំវិញ។ អ្នកខ្លះតាមផ្ញើសារសួរទៀត ថាហេតុអីបានជាសរសេរបែបនេះ? សូមកុំច្រលំថា ខ្ញុំជាមនុស្សដែលខ្វល់ពីអ្នកដទៃឱ្យសោះ

ព្រោះការខ្វល់របស់ខ្ញុំមានកម្រិត ហើយនៅក្នុងកម្រិតនោះ គ្មានឈ្មោះមនុស្សដែលខ្ញុំមិនស្គាល់ទេ។ សូម្បីតែមិត្តភក្តិធម្មតា ឬអ្នកធ្វើការជាមួយគ្នា ក៏ខ្ញុំមិនខ្វល់ដែរ។

ខ្ញុំចង់សរសេរអី ជាចំណូលចិត្តរបស់ខ្ញុំ ដូច្នេះការមកសួររកហេតុផលបែបនេះ ជារឿងគ្មានប្រយោជន៍ទេ។ ពេលជួបរឿងបែបនេះ ខ្ញុំគ្មានមធ្យោបាយផ្សេង ក្រៅពីប្រើពាក្យអាក្រក់ទៅវិញ ឬ block ចោលតែម្តង ដើម្បីកុំឱ្យមករំខានទៀត។ ពួកគេគ្មានអ្វីត្រូវមកសួរនាំខ្ញុំច្រើនបែបនេះទេ។ បើមិនពេញចិត្ត កុំអាន ឬបើអានហើយមិនពេញចិត្ត ទៅជុះនោមឱ្យអស់ចិត្តខឹងទៅបានហើយ។

ខ្ញុំបង្កើតផេកដើម្បីសរសេរឱ្យស្ទាត់ដៃ និងរៀបចំគំនិតថ្មីសម្រាប់សៀវភៅក្រោយៗរបស់ខ្ញុំប៉ុណ្ណោះ។ សៀវភៅខ្លះ កើតចេញពីការផុសជា status ប្រចាំថ្ងៃនៅលើផេករបស់ខ្ញុំ។ ខ្ញុំធ្វើមានគោលបំណងច្បាស់ណាស់ គឺដើម្បីលក់សៀវភៅ មិនមែនដើម្បីឱ្យគេចូលចិត្ត ឱ្យគេមកពិភាក្សា ឬមកសួរនាំខ្ញុំដូចអ្នកទោសទេ។

ខ្ញុំមិនខ្វល់ថាគេហៅខ្ញុំ “បង” ឬហៅឈ្មោះខ្ញុំដូចអ្នកធ្លាប់ស្គាល់គ្នាទេ បើមិនមែនជាមនុស្សដែលខ្ញុំត្រូវខ្វល់ ខ្ញុំមិនចង់និយាយជាមួយតែម្តង។ សម្រាប់អ្នកដែលទើបនឹងធំ ឬអាយុច្រើនតែមិនសូវដឹងខ្យល់ អាចនឹងគិតថា ខ្ញុំជាមនុស្សវាយឬក ប៉ុន្តែការវាយឬក ឬមិនវាយឬក ស្ថិតលើភាពសំខាន់ និងការកំណត់របស់ខ្ញុំ។ បើខ្ញុំទៅឆ្លើយឆ្លងជាមួយមនុស្សទាំងនេះនៅលើអ៊ីនធឺណេត ខ្ញុំត្រូវខាតពេលធ្វើកិច្ចការផ្ទាល់ខ្លួន។ ខ្ញុំសុខចិត្តដេកលេងជាមួយសត្វ ក៏ខ្ញុំមិនឆ្លើយតបសាររបស់ពួកនេះដែរ ព្រោះពួកគេមិនមែនជាអ្នកដែលខ្ញុំត្រូវខ្វល់។ មនុស្សដែលមិនត្រូវខ្វល់ គ្មានតម្លៃនឹងឱ្យយើងចំណាយពេលវេលាជាមួយទេ។

កុំប្រលំថា ខ្ញុំមិនចេះធ្វើទំនាក់ទំនងជាមួយអ្នកអានឱ្យសោះ។ ខ្ញុំដឹងថា អ្នកណាជាអ្នកអានរបស់ខ្ញុំ ហើយខ្ញុំដឹងថា អ្នកណាគេចង់យល់ពីអ្វីដែលខ្ញុំសរសេរពិតប្រាកដ មិនមែនគ្រាន់តែសួរដើម្បីឈ្លោះគ្នា ឬចង់កាច់កុងនឹងខ្ញុំ។ ខ្ញុំមានអ្នកអានដែលផ្ញើបញ្ហារបស់សៀវភៅខ្ញុំ ឬកំហុសក្នុងសៀវភៅឱ្យ ហើយខ្ញុំពិតជាអរគុណពួកគេណាស់ ព្រោះពួកគេជួយប្រាប់ពីកំហុសដែលខ្ញុំមាន។ គេបង្ហាញមកថា គេខ្វល់ពីសៀវភៅខ្ញុំ ដូច្នេះខ្ញុំត្រូវចំណាយពេលខ្វល់ជាមួយពួកគេវិញ។ ពេលខ្លះ ខ្ញុំនិយាយជាមួយអ្នកទិញសៀវភៅខ្ញុំដល់ ១ម៉ោងក៏មានដែរ។ គេខ្វល់ពីស្នាដៃខ្ញុំ រឿងអីដែលខ្ញុំមិនខ្វល់ពីគេវិញ?

ខ្ញុំរៀនបែងចែកមនុស្សដែលត្រូវខ្វល់ និងមិនត្រូវខ្វល់ដាច់ពីគ្នា។ ខ្ញុំសរសេរពីអ្នកនយោបាយ មិនមែនបានន័យថាខ្ញុំខ្វល់ពីពួកគេទេ តែខ្ញុំខ្វល់ពីចំណុចដែលត្រូវសរសេរក្នុងសៀវភៅប៉ុណ្ណោះ។ ការសរសេរពីអ្នកនយោបាយ ជាប្រធានបទមួយគួរឱ្យចាប់អារម្មណ៍ និងបង្រៀនមនុស្សឱ្យចេះគិតកាន់តែជ្រៅ។ ខ្ញុំនៅក្មេង ហេតុនេះការគិតរបស់ខ្ញុំមិនទាន់ចំចំណុច តែខ្ញុំក៏គ្មានបំណងសរសេរចំចំណុចដែរ ព្រោះខ្លាចអាយុខ្លី។ ខ្ញុំសរសេរជាលក្ខណៈទូទៅ តែក្នុងក្រសែភ្នែកអវិជ្ជមាន។ កុំចង់ធ្វើជាអ្នកវិភាគតាមសំណេរ ព្រោះសំណេរជាភស្តុតាងដែលយើងគេចមិនផុត ពេលគេតាមរករឿង។ បើយើងជាពងមាន់ កុំចង់ឱ្យថ្មទម្លាក់ខ្លួនមកសង្កត់។

បើមិនដឹងទេ ខ្ញុំអាចប្រាប់បាន។ ខ្ញុំមើលពិភពលោកក្នុងផ្លូវអវិជ្ជមាន ព្រោះពិភពលោកសព្វថ្ងៃ មានរឿងអវិជ្ជមានច្រើនណាស់។ សូម្បីតែរឿងវិជ្ជមានខ្លះ ដូចជា ការអប់រំ ការរៀបការ ការស៊ីចុក ការប្រើតិចណូឡូជី ឬរបៀបចិញ្ចឹមកូន ក៏ក្លាយជារឿងអវិជ្ជមានដែរ។ ប៉ុន្តែខ្ញុំចេះគិតវិជ្ជមាននៅពេលខ្ញុំធ្វើការ និងរស់នៅជាមួយមនុស្សសំខាន់ៗរបស់ខ្ញុំ។ ខ្ញុំមិនមែនជាមនុស្សប្រភេទតែស្ដុករល្អគ្រប់កន្លែងទេ ព្រោះអ្វីដែលខ្ញុំមើលឃើញ និងអ្វីដែលធ្លាប់

ឆ្លងកាត់បញ្ជាក់ថា សារជាតិមនុស្ស គឺអាក្រក់ ច្រើនជាងល្អ ហើយរឿងអវិជ្ជមានថ្មីកំពុងតែកើតឡើងបន្តទៀតដែរ តែខ្ញុំមិនខ្វល់ទេ។

# ៦

# ទាល់តែដេកលក់ទើបស្រួលមើរតាមគេ

អ្នកដែលគេភ្ញាក់ខ្លួន គេនឹងមិនវង្វេងតាមពាក្យរបស់អ្នកណាទាំងអស់ មិនថាអ្នកនោះពូកែប្រើពាក្យលួងលោម ឬប្រើទ្រឹស្តីមកបោកទេ។ គេមើលឃើញពីបំណងខ្លះៗរបស់អ្នកដែលចង់ធ្វើជាមេដឹកនាំ។ គេមិនអាចមើលឃើញទាំងអស់ទេ ព្រោះអ្នកដែលមានមហិច្ឆតាធំ ពូកែបិទបាំងណាស់។

យើងអាចនិយាយបានថា នៅពេលពួកគេដេកលក់ ពួកគេមមើរតាមពាក្យរបស់អ្នកនយោបាយ ហើយរីករាយនឹងការប្រឌិតឡើងរបស់ពាក្យទាំងនោះ។ វេបសាយសុខភាពរបស់ខ្មែរយើងមួយ បានសរសេរថា “បើយើងដេកមមើរ យើងត្រូវតែរកវិធីព្យាបាល” ប៉ុន្តែបេ ៊ី អ្នកដែលដេកមមើរមិនចង់ព្យាបាល ក៏យើងមិនអាចធ្វើអ្វីបានដែរ។

គេដេកលក់ គេសប្បាយចិត្ត ព្រោះមិនបាច់ខ្វល់ថា តើអំណាចរបស់អ្នកនយោបាយ មានឥទ្ធិពលអាក្រក់ដល់សេរីភាពរបស់ប្រជាជនធម្មតាយ៉ាងណាទេ។ ពួកគេមិនគិត ហើយក៏មិនចង់គិតពីចំណុចអាក្រក់របស់អ្នកនយោបាយដែរ។ វាជារឿងងាយស្រួលដែលជ្រើសយកទង់នយោបាយណាមួយដើម្បីជ្រកកោន ប្រសើរជាងឈរហាលថ្ងៃដូចខ្ញុំ។ ខ្ញុំក៏ចង់បានម្លប់ដែរ តែម្លប់ដែលនៅក្រោមជើងស្អុយរបស់អ្នកនយោបាយបែបនេះ ខ្ញុំមិន

អាចទ្រាំបាន។ ខ្ញុំមិននៅប្រឡោះកណ្ដាលដូចស្ដេចសីហនុទេ។ គាត់និយាយតែមាត់ប៉ុណ្ណោះ តែរត់ទៅរកខាងចិនយូរមកហើយ។ ខាងណាក៏ខ្ញុំមិនពេញចិត្ត ខាងណាក៏ខ្ញុំមិនគាំទ្រ តែបើគេឱ្យលុយខ្ញុំ ខ្ញុំនឹងធ្វើពុតជាគាំទ្រឱ្យត្រូវនឹងតម្លៃ។ ជាមួយអ្នកនយោបាយ មានតែតាំងខ្លួនជាមនុស្សមុខលុយ ទើបអាចរស់បានស្រួល ហើយរស់បានយូរ។

ខ្ញុំមិនអាចស្មោះត្រង់នឹងអ្នកនយោបាយទេ ព្រោះវាមិនអាចទៅរួច ដែលខ្ញុំត្រូវមានស្មោះត្រង់តែឯង ហើយគេប្រើល្បិចគ្រប់ពេលបែបនេះ។ ដូចខ្ញុំប្រាប់អ៊ីចឹង ទោះបីជាខ្ញុំមិនទទួលស្គាល់អ្នកនយោបាយណាជាមនុស្សល្អ និងធ្វើជាមេលើក្បាលខ្ញុំ ក៏ខ្ញុំគេចមិនផុតពីត្រូវគេត្រួតត្រាដែរ។ ខ្ញុំនៅពីក្រោមអំណាចគេដូចគ្នា តែខ្ញុំមានសេរីភាពក្នុងការគិត និងមិនចាំបាច់ប្ដូរស្លាប់ដើម្បីមនុស្សដែលពាក់អាវធំ។

អ្វីដែលខ្ញុំសរសេរនេះ គឺមានតែអ្នកដែលភ្ញាក់ខ្លួន និងចង់ភ្ញាក់ខ្លួនប៉ុណ្ណោះទើបអាចយល់បាន។ អ្នកដែលចង់ដេកលក់ ទោះបីជាអានប៉ុន្មានដងទៀតក៏នៅតែមិនយល់ ហើយបានត្រឹមតែរកពាក្យជេរខ្ញុំប៉ុណ្ណោះ។ កុំជេរខ្ញុំឱ្យខាតពេលអី ទៅដេកបន្តទៅ ទាន់អ្នកនយោបាយនៅមានបទច្រៀងបំពេរ។

ខ្ញុំចាំបានថា ពេលបណ្ឌិតកែមឡីស្លាប់ភ្លាម ខ្ញុំបានសរសេរអត្ថបទមួយដែលចោទប្រកាន់ថា “ការស្លាប់របស់គាត់ គឺមកពីយើងទាំងអស់គ្នាដែលមិនចេះរៀនស្វែងយល់ដោយខ្លួនឯង ហើយចាំឱ្យគាត់និយាយចំៗពេក”។ ខ្ញុំត្រូវបានគេជេរថា “អាពួកទ្រពង” ព្រោះគេគិតថា ខ្ញុំជួយសរសេរលើកជើងគណបក្សណាមួយ។ ខ្ញុំគ្មានអីតបទេ ព្រោះទោះបីតប ក៏អ្នកដែលជេរខ្ញុំមិនយល់ដដែល ហេតុនេះខ្ញុំក៏ទុកឱ្យគេជេរទៅ។ អ្វីដែលអស្ចារ្យគឺពួកគេមិនជេរទៀតទេ។ ដឹងថាហេតុអីទេ? ពួកនេះជាប្រភេទមនុស្សតាមគ្នា ដូច្នេះអ្វីដែលគេធ្វើ គឺមួយឆាវប៉ុណ្ណោះ។

មានរឿងខ្លះប្រហែលជាអ្នកទាំងអស់គ្នាមិនដែលសម្គាល់ ដូច្នេះចាំខ្ញុំប្រាប់។ អ្នកដែលគាំទ្រអ្នកនយោបាយណាក៏ដោយ ដែលលះបង់ចិត្តស្មោះ កម្លាំងកាយ កម្លាំងជេរ សុទ្ធតែជាមនុស្សទ្រពង។ ការទ្រពងអ្នកនយោបាយ ជាកម្រិតថោកមួយដែលខ្ពស់បំផុត ក្នុងចំណោមការទ្រពងទាំងអស់។ ខ្ញុំឆ្ងល់ដល់ហើយ ពងអ្នកនយោបាយដូចជាមិនធំប៉ុន្មានទេ ហេតុអីបានជាមនុស្សទៅទ្រច្រើនម្ល៉េះ? ខ្ញុំនិយាយឱ្យស្រួលស្តាប់ អ្នកនយោបាយដូចជាមិនអាចជួយអ្វីយើងបានច្រើនទេ ហេតុអ៊ីក៏នាំគ្នាគាំទ្រច្រើនម្ល៉េះ? ដឹងថាអ្នកណាដែលអាចជួយយើងបានទេ? គឺខ្លួនយើង និងមនុស្សដែលយើងត្រូវខ្វល់។

អ្នកណាចង់ដេកមមើរ ក៏ដេកទៀតចុះ ព្រោះនេះជាសិទ្ធិភ្លើៗរបស់យើង។ ហើយកុំជេរគេ ពេលឃើញគេភ្ញាក់ខ្លួន ហើយយើងមិនយល់ពីអ្វីដែលគេលើកឡើង។ បើយើងភ្លើខ្លួនឯងហើយ ទៅដើរស្តីឱ្យគេដែលដឹងច្រើនជាងយើងទៀត យើងកាន់តែភ្លើទៅៗហើយ។

# ៧

# បើយើងមិនមែនជាអ្នកនយោបាយ កុំចង់អូសទាញគេ

សូមកុំស្រមៃថា យើងអាចអូសទាញគេឱ្យគិតដូចយើង ឬមើលឃើញអ្វីដែលយើងឃើញឱ្យសោះ ព្រោះយើងគ្មានសមត្ថភាពបែបនោះទេ។ ការអូសទាញ ជាជំនាញរបស់អ្នកនយោបាយ និងគ្នីគ្នាគេប៉ុណ្ណោះ។ ខ្ញុំមិនច្បាស់ថា គេប្រើវិធីអ្វីខ្លះដើម្បីទប់ខួរក្បាលរបស់អ្នកដែលត្រូវគេអូសទាញកុំឱ្យគិតអ្វីនោះទេ តែវាមានប្រសិទ្ធិភាពណាស់។

ការអូសទាញអ្នកដទៃ ដោយយើងមិនអាចបានប្រយោជន៍អ្វី ជាការខាតពេល ហេតុនេះមិនបាច់ធ្វើទេ។ បើគេចង់ជឿលើអ្នកណា ឱ្យគេជឿទៅ ហើយបើគេមកនិយាយជាមួយយើងដោយមានបំណងអូសទាញយើងវិញ យើងត្រូវធ្វើចិត្តដាច់ រៀបពាក្យគ្រប់ប្រភេទដាក់ឱ្យអ្នកនោះបិទមាត់ផង។ ត្រូវចាំ បើគេបម្រុងជេរយើង ត្រូវជេរឱ្យបានមុន ហើយជេរឱ្យជ្រៅ។ កុំឱ្យពួកនេះបានចិត្ត ហើយត្រូវឱ្យគេដឹងថា យើងមិនចូលចិត្តមនុស្សទ្រពងអ្នកនយោបាយទេ។

កុំធ្វើជាមនុស្សល្អ ជាមួយមនុស្សអាក្រក់ ព្រោះបើយើងធ្វើបែបនេះ យើងនឹងចាញ់គេ។ ការចាញ់របស់យើង នឹងប្រាប់ពិភពលោកថា មនុស្សអាក្រក់អាចឈ្នះមនុស្សល្អគ្រប់ពេល។ អ្នកដទៃឃើញបែបនេះ នឹងរើសផ្លូវអាក្រក់ដើម្បីដើរដែរ ព្រោះយល់ថា ផ្លូវរបស់មនុស្សអាក្រក់ ជាផ្លូវឈ្នះ។ យើងត្រូវរៀនធ្វើជាមនុស្សអាក្រក់ នៅចំពោះមុខមនុស្សអាក្រក់ ព្រោះមានតែអាក្រក់ជាងទេ ទើបឈ្នះអាក្រក់ធម្មតា ឬអាក្រក់តាមគ្នាបាន។

យើងមិនបាច់ទៅអូសទាញគេទេ ហើយក៏មិនត្រូវឱ្យគេអូសទាញយើងដែរ។ ត្រូវចាំ មនុស្សអូសគោឱ្យដើរ ដូច្នេះបើយើងមិនមែនជាគោ ហើយយើងមិនចង់ដើរតាមគេ កុំទុកឱកាសឱ្យគេនិយាយពង្វក់យើង។ កុំឱ្យមនុស្សអាក្រក់គិតថា មានតែឯងដែលអាចនិយាយចាក់ដោតចិត្តគេបាន យើងក៏អាចធ្វើបានដែរ។ រៀនប្រើពាក្យជ្រៅៗ ពាក្យឌឺដង ឬរៀនបិទមាត់គេ (មិនមែនថើបគ្នាទេ) ដើម្បីអាចចាត់ការជាមួយដៃជើងអ្នកនយោបាយបាន។ ពួកគេនឹងមកអូសទាញយើងនៅពេលណាមួយ បើយើងមិនអាចទប់បាន យើងនឹងត្រូវគេអូសទាញ ឬត្រូវគេមើលងាយ។

បំណងល្អរបស់ខ្ញុំ គឺយើងត្រូវរៀនធ្វើជាមនុស្សអាក្រក់ ដើម្បីរស់នៅជាមួយមនុស្សអាក្រក់។ អ្នកដែលគាំទ្រនយោបាយ និងអ្នកនយោបាយ ជាមនុស្សអាក្រក់។ ខ្ញុំអាចនឹងគិតខុស តែក្នុងពេលឥលូវនេះ ពួកគេជាមនុស្សអាក្រក់ពិតមែន។ បើខ្លួនយើងល្អ យើងមិនបាច់ចាំបាច់ភ័យថា បើធ្វើមនុស្សអាក្រក់ហើយ មិនអាចត្រលប់មកធ្វើមនុស្សល្អបានទេ។ យើងមិនមែនធ្វើអាក្រក់ដើម្បីក្លាយជាអាក្រក់ទេ តែយើងធ្វើដើម្បីទប់នឹងមនុស្សអាក្រក់។

អំពើល្អ អាចឈ្នះអំពើអាក្រក់តែនៅក្នុងរឿងប៉ុណ្ណោះ ក្នុងជីវិតពិត អំពើល្អនឹងនាំយើងឱ្យបរាជ័យ។ បរាជ័យដែលខ្ញុំលើកមកនេះ គឺពេលដែលខួរក្បាលយើងមិនអាចគិតអ្វីចេញ និងពេលត្រូវគេមកអូសទាញ។ យើង

បណ្តោយឱ្យគេធ្វើអ្វីតាមចិត្ត នៅពេលដែលខ្លួនយើងក៏មានខួរក្បាលមួយនឹងគេដែរ។

សរុបមក កុំចង់ដណ្តើមការងាររបស់អ្នកនយោបាយ។ ការងារយើងមាន កធ្វើទៅ កុំចំណាយពេលអូសទាញគេដោយគ្មានផល។ អ្នកនយោបាយ គេអូសទាញមនុស្សដើម្បីពង្រីកអំណាច និងឈ្មោះគេ ចុះយើងប្រឹងអូសទាញគេដើម្បីពង្រីកអីដែរ? ឱ្យអ្នកខឹងយើងច្រើន ឬឱ្យមានអ្នកស្អប់យើងច្រើន? បើគ្មានបានផលស្មើអ្នកនយោបាយទេ កុំបាច់ចង់ធ្វើ។ រស់នៅជាមួយអ្នកនយោបាយ ត្រូវចេះរៀនឆ្លាតតាមគេខ្លះ។

# ៨

# ជួយដោយគ្មានគេសុំ

Sam Levenson បាននិយាយថា “នៅពេលអ្នកកាន់តែចាស់ទៅ អ្នកនឹងដឹងថា អ្នកមានដៃពីរ។ ដៃមួយ គឺសម្រាប់ជួយខ្លួនឯង ហើយដៃមួយទៀតគឺសម្រាប់ជួយអ្នកដទៃ”។ Sam មិនមែននិយាយពីការជួយខ្លួនឯងក្នុងផ្លូវភេទទេ ដូច្នេះសូមកុំច្រលំ។ ពេលខ្លះ ការបកប្រែពីភាសាគេមកភាសាយើង ធ្វើឱ្យវាមិនសូវច្បាស់។

ការដែលយើងឃើញគេខុស ឬពិបាក ហើយបំណងជួយគេ គឺជាការល្អ។ វាបង្ហាញថា យើងជាមនុស្សល្អ មានចិត្ត ប៉ុន្តែបើជួយដោយគ្មានគេសុំ យើងអាចនឹងក្លាយជាមនុស្សល្អ ដែលនាំទុក្ខដាក់ខ្លួន។ គេមិនដឹងពីចិត្តយើងទេ តែគេនឹងប្រកាន់ បើយើងចេះដឹងរឿងគេជ្រុលពេក។ ខ្ញុំធ្លាប់ជួបច្រើនដងហើយ។ កុំគិតថា ខ្ញុំមិនដែលជួយអ្នកដទៃឱ្យសោះ។

យើងឃើញឧទាហរណ៍ស្រាប់ ដូចអ្នកដែលងប់នឹងមន្តស្នេហ៍សំនៀងរបស់អ្នកនយោបាយ។ ពួកគេនឹងខឹង ឬស្អប់ អ្នកដែលព្យាយាមដាស់គេឱ្យភ្ញាក់ពីមន្តស្នេហ៍នេះ។ គេមិនបានសុំយើងឱ្យជួយបកស្រាយ ឬបើកផ្លូវឱ្យគេមើលឃើញពីរឿងអាក្រក់របស់អ្នកនយោបាយទេ។ គេមិនដែលសុំយើងឱ្យជួយមួយម៉ាត់ទេ ព្រោះគេគិតថា យើងទៅវិញទេ ដែលត្រូវការគេជួយ។ ខ្ញុំសូមនិយាយបែបមើលងាយបន្តិចចុះ “ឋានៈត្រឹមអ្នកដែលដើរតាមអ្នកនយោបាយគ្រប់ពេល តែគ្មានបានអ្វីដុំកំភួន គ្មានអ្វីមកជួយខ្ញុំបានទេ”។ យើងត្រូវដឹងថា តើអ្នកណាត្រូវការគេជួយពិតប្រាកដ?

ខ្ញុំមិនដែលសុំឱ្យអ្នកនយោបាយមកជួយរកលុយឱ្យខ្ញុំចាយទេ។ អ្នកនយោបាយដែលជាប់ឆ្នោត មិនដែលខ្វល់ពីគ្រួសារខ្ញុំ។ អ្នកនយោបាយដែលចង់ជាប់ឆ្នោត ក៏មិនរវល់នឹងគ្រួសារខ្ញុំ ហេតុនេះពេលខ្ញុំធំឡើង ខ្ញុំក៏មិនខ្វល់ជាមួយអ្នកនយោបាយដែរ។ ខ្ញុំរស់ដោយគ្មានជំនួយពីអ្នកនយោបាយ ទោះបីខ្ញុំរស់ក្រោមការគ្រប់គ្រងរបស់ពួកអ្នកនយោបាយក៏ដោយ។

អ្វីដែលខ្ញុំសរសេរនៅលើអ៊ីនធឺណេត អំពីរឿងអាក្រក់របស់អ្នកនយោបាយ គឺមានគោលបំណងឱ្យអ្នកអានបានគិតប៉ុណ្ណោះ។ ខ្ញុំដឹងថាគេមិនត្រូវការខ្ញុំជួយទេ ហេតុនេះខ្ញុំក៏មិនចំណាយពេលច្រើនជាមួយពួកគេដែរ។ បើគេមិនសុំឱ្យជួយ ខ្ញុំមិនជួយ។ ខ្ញុំមិនធ្វើរឿងដែលគេមិនត្រូវការទេ។ ទោះបីជាគេសុំឱ្យជួយ ក៏ខ្ញុំមិនប្រាកដថាត្រូវជួយដែរ ព្រោះវាមិនមែនជារឿងរបស់ខ្ញុំ។ ខ្ញុំបញ្ជាក់រួចហើយថា មនុស្សដែលខ្ញុំត្រូវខ្វល់ មានគ្រប់គ្រាន់នឹងធ្វើឱ្យខ្ញុំរវល់អស់មួយជីវិតទៅហើយ ដូច្នេះសម្រាប់អ្នកផ្សេងទៀត មានតែត្រូវប្រើពាក្យ "ខ្លួនទីពឹងខ្លួន"។

# ៩

# គតដល់នយោបាយ និង សាសនាផង

នៅពេលអ្នកទាំងអស់គ្នាគិតដល់សាសនា និងនយោបាយ អ្នកទាំងអស់គ្នានឹងដឹងថា តើគួរនៅមានបំណងដាស់អ្នកដទៃទៀតឬអត់? ពិភពលោកនេះត្រូវបានបំផ្លាញទាំងស្រុងតាំងពីពេលដែលសាសនា និងនយោបាយគ្រប់គ្រងមកម្ល៉េះ។ តើយើងនៅចង់បានអីទៀត បើវាអស់ផ្លូវកែទៅហើយហ្នឹង?

ខ្ញុំគ្មានសង្ឃឹមថា មនុស្សនឹងរកឃើញផ្លូវរស់នៅដោយមានក្ដីសុខទេ។ សាសនា បង្កើតសង្គ្រាម និងការស្អប់គ្នាទៅវិញទៅមក។ នេះមិនទាន់រាប់ដល់ ការបោកប្រាស់លុយ ការសម្លាប់មនុស្សដោយប្រយោល ការខ្ជះខ្ជាយពេលវេលា និងបញ្ហាពង្វក់ខួរក្បាលក្មេងផង។ សាសនា មានចំណុចល្អ តែបើយកមកថ្លឹងថ្លែងនឹងចំណុចអាក្រក់ដែលវាមាន យើងនឹងឃើញថាចំណុចល្អទាំងនោះ គ្មានអ្វីអស្ចារ្យទេ។

យើងអាចនឹងឆ្ងល់គិតថា សាសនា ជាពាក្យប្រៀនប្រដៅមនុស្សពីរបៀបរស់នៅ តែនេះមិនមែនជាវិធីតែមួយដើម្បីប្រដៅមនុស្សទេក្នុងពេលនេះ។ សៀវភៅ ការបង្រៀន ការសម្ភាសន៍ និងប្រភពចំណេះដឹងជាច្រើនត្រូវគេដាក់បញ្ចូលទៅក្នុងអ៊ីនធឺណេតដើម្បីជួយប្ដូរទិសដៅរបស់ពិភពលោក។ យើងលែងត្រូវការសាសនា តាំងពីវិទ្យាសាស្រ្តចាប់ផ្ដើមងើបឡើងម្ល៉េះ។

សាសនា ក្លាយជាមេរោគសង្គមមួយទៅហើយនៅពេលនេះ។ វាបង្រៀនឱ្យមនុស្សខ្ជិល ឆាប់ជឿ ស្អប់អ្នកដទៃ និងរស់ដើម្បីស្លាប់ទៅនៅជាមួយព្រះ។ អ្វីដែលអាក្រក់បំផុត គឺសាសនា តែងតែឈរជាមួយអ្នកនយោបាយ។ បើសាសនា ជារបស់ល្អ ហេតុអីបានជាវានៅជាមួយនឹងមនុស្សអាក្រក់។ ខ្ញុំនៅតែមិនយល់ពីចំណុចនេះ។ អ្នកនយោបាយ មិនអាចមានចិត្តល្អបានទេ ព្រោះវាផ្ទុយពីមហិច្ឆតាគ្រប់គ្រងគេ។ អ្នកចិត្តល្អ មិនចង់រស់នៅជិះជាន់អ្នកណាទេ ព្រោះគេជឿលើភាពស្មើគ្នារបស់មនុស្ស។

សាសនា ជួយបំផ្លាញ និងគ្រប់គ្រងផ្លូវចិត្តមនុស្ស។ នយោបាយ ជួយបំផ្លាញ និងគ្រប់គ្រងសកម្មភាពរបស់មនុស្ស។ តើយើងមានសេរីភាពមកពីណាទៀត បើគេគ្រប់គ្រងយើងទាំងពីរផ្លូវហើយហ្នឹង? បើមិនជឿ សាកគិតបន្តិចទៅមើល តើផ្នែកណាមួយនៃជីវិតយើងដែលមិនជាប់ពាក់នឹងសាសនា និងនយោបាយ? អត់មានទេ។ យើងរស់នៅក្នុងទ្រុងដែលមើលមិនឃើញ ហើយយើងបោកខ្លួនឯងថា យើងមានសេរីភាព។ ហេតុនេះបានជាគេថា យើងមិនអាចមើលងាយភាពភ្លើរបស់មនុស្សបានទេ។ វាគ្មានដែនកំណត់ នៅពេលមនុស្សភ្លើដល់កម្រិត។

សាសនា និងនយោបាយ ជួយគ្នាទៅវិញទៅមក ដើម្បីជួយមនុស្សតែមួយក្រុមតូច អាចបន្តគ្រប់គ្រងមនុស្សរាប់លាននាក់បាន។ បើយើងមើលមិនឃើញពីចំណុចនេះ ក៏មិនចំលែកដែរ ព្រោះមនុស្សមួយក្រុមតូចនោះបានព្យាយាមរកវិធីពង្វក់យើង មិនឱ្យគិតពីរឿងនេះ។ គេចំណាយលុយ និងជីវិតមនុស្សច្រើនណាស់ ដើម្បីកុំឱ្យអ្នកដែលនៅក្រោមបង្គាប់គេចេះគិតបែបនេះ។

សាសនា និងនយោបាយ គ្រប់គ្រងពិភពលោកយូរហើយ ដូច្នេះខ្ញុំគ្មានសង្ឃឹមអីទេ។ ខ្ញុំរស់នៅដោយទទួលស្គាល់ការពិតនេះ ហើយធ្វើអ្វីដែលខ្ញុំ

អាចធ្វើបាន ដោយមិនខ្វល់ពីទ្រឹស្តីអាចម៍ឆ្កែរបស់អ្នកណាទាំងអស់។ ខ្ញុំម្នាក់ឯង តូចពេក រហូតមិនអាចយកទៅប្រៀបនឹងសាសនា ឬនយោបាយបាន។ សាសនា និងនយោបាយ កើតមុនខ្ញុំ ដូច្នេះឥទ្ធិពលរបស់វាក៏ខ្លាំងជាងអ្នកនិពន្ធសៀវភៅកំប៉ិកកំប៉ុកដូចខ្ញុំដែរ។ ខ្ញុំមិនយកពងមាន់ទៅជល់នឹងខ្នះក្តៅទេ ហេតុនេះអ្នកណាចង់ជឿអី ក៏ជឿទៅ ខ្ញុំគ្មានបំណងចង់ដាស់ទេ។

អ្វីដែលខ្ញុំចង់បាន គឺរស់នៅដោយសេរីភាពដែលខ្ញុំអាចយកបាន ហើយខ្ញុំចង់មើល សាសនា និងនយោបាយបំផ្លាញពិភពលោកនេះបន្តទៀត។ ខ្ញុំមិនលូកដៃជួយ ហើយក៏មិនស្តាយក្រោយដែរ ព្រោះនេះមិនមែនជាកំហុសរបស់ខ្ញុំ។ ខ្ញុំមិនមែនជាគ្រីស្តសាសនិក ដែលជឿថាពួកគេគេមានកំហុសតាំងពីកើតមកទេ។ កំហុសដែលខ្ញុំធ្លាប់ធ្វើ គឺមានចិត្តចង់ជួយអ្នកដទៃ ទាំងគេមិនបានសុំឱ្យជួយ។

លើកក្រោយ ពេលគិតចង់ជួយដាស់តឿនអ្នកណាម្នាក់ ត្រូវយកខ្លួនយើងទៅប្រៀបនឹង សាសនា ឬនយោបាយសិន។ បើយើងធំមិនដល់ទេ កុំគិតអីសម្រាកទៅ។ ជួយមនុស្សដែលយើងខ្វល់ ឱ្យរួចពីការលំបាកទៅ ល្អជាង។

# ១០

# ដឹងថាហេតុអីគេមិនចង់ឱ្យយើងរៀនច្រើនពេកទេ?

សាលារៀន មិនមែនជាកន្លែងសម្រាប់រៀនពិតប្រាកដទេ វាជាកន្លែងសម្រាប់ផលិតពលរដ្ឋឱ្យអ្នកនយោបាយ។ ពលរដ្ឋ បានន័យថា ពលដែលស្ម័គ្រស្លាប់ដើម្បីរដ្ឋ តែដោយសារអ្នកនយោបាយជាអ្នកកាន់កាប់រដ្ឋភាគច្រើននៃពលរដ្ឋ ត្រូវស្ម័គ្រស្លាប់ដើម្បីអ្នកនយោបាយវិញ។ ទាក់ទងនឹងអំណាច គឺងាយយល់ណាស់។ អ្នកណាក្ដាប់អំណាច អ្នកនោះក្ដាប់ពលរដ្ឋ និងក្ដាប់អ្វីផ្សេងទៀតដែលយើងមិនដឹង។

យើងអាចឃើញច្បាស់ថា សាលារៀន បង្រៀនក្មេងពីអីខ្លះ។ មេរៀនមានច្រើនណាស់ តែគេជ្រើសយកមេរៀនណាដែលចាំបាច់ក្នុងការបង្កើតទស្សនៈចៀម ទៅឱ្យក្មេង ដូចជា បង្រៀនពីសាសនា បង្រៀនឱ្យសរសើរយុទ្ធសាស្ត្ររបស់អ្នកនយោបាយ រៀនសរសើរពីអំណួតរបស់ស្ដេចពីដើមដែលចំណាយជីវិតមនុស្សទៅសង់ប្រាសាទ និងរៀនពីរបៀបអែបអបអ្នកដែលធំជាង។ សិស្សធំមិនទាន់ ចេះអែបអបគ្រូដោយប្រើពាក្យសរសើរ ឬទិញរបស់ឱ្យដើម្បីប្ដូរពិន្ទុ។

Robert Kiyosaki បានសរសេរក្នុងសៀវភៅ Rich Dad Poor Dad ថា “សាលារៀនក្លាយជាចំណុចបញ្ចប់របស់មនុស្សទៅវិញ”។ វាជាចំណុច

បញ្ចប់របស់យើងមែន តែវាចំណុចចាប់ផ្ដើមរបស់អ្នកនយោបាយ។ គេត្រូវការផលិតមនុស្សដែលចេះគិតល្មម យកមកប្រើការបាន តែមិនត្រូវចេះគិតខ្លាំងពេកទេ ព្រោះអាចប៉ះពាល់ដល់មហិច្ឆតារបស់គេ។ អ្នកនយោបាយស្រលាញ់មហិច្ឆតាគេណាស់ ហេតុនេះគេមិនបង្កើតគ្រោះថ្នាក់ដល់ខ្លួនគេឡើយ។ អ្នកនយោបាយនៅប្រទេសណាក៏ដោយ ខ្លាចជាងគេ គឺប្រជាជនដែលចេះគិត ហើយចេះដកជំនឿចេញពីប្រព័ន្ធរបស់អ្នកមានអំណាច។ គេទុកប្រជាជនដែលចេះគិត ជាមនុស្សគ្រោះថ្នាក់ ហេតុនេះគេតែងតែមិនរវល់ជាមួយមនុស្សបែបនោះទេ។ បើទាល់ច្រក គេសម្លាប់ចោលតែម្ដង។

នៅពេលយើងរៀនស្រាវជ្រាវ និងសង្កេតដោយខ្លួនឯងកាន់តែច្រើន យើងនឹងដឹងថា គ្រប់យ៉ាងដែលគេប្រាប់យើង ជាពាក្យកុហកទាំងអស់។ វាសមហេតុផល តែវាមិនមែនជាការពិត។ មិនមែនការពិតទាំងអស់ សុទ្ធតែនៅកណ្ដាលវាលនោះទេ។ ការពិតខ្លះ អាចផ្លាស់ប្ដូរអំណាចអ្នកនយោបាយបាន ហេតុនេះគេយកវាទៅលាក់អស់ហើយ។ គេបង្ហាញតែការពិតធម្មតាៗឱ្យយើងដឹងប៉ុណ្ណោះ ហើយយើងដែលល្ងង់មិនចេះរកការពិត ក៏គិតថា គេជាមនុស្សស្មោះត្រង់ ព្រោះគេប្រាប់ការពិតដល់យើង។

គេមិនចង់ឱ្យយើងចេះច្រើន ព្រោះខ្លាចពិបាកគ្រប់គ្រង។ គេចង់គ្រប់គ្រងយើងឱ្យដូចសត្វនៅក្នុងទ្រុង តែគេមិនប្រាប់យើងបែបនេះទេ។ បើគេប្រាប់បែបនេះ យើងនឹងខឹងគេ ហើយលែងជឿគេ។ គេក៏បង្កើតហេតុផលឱ្យយើងជឿថា អ្វីដែលគេធ្វើ គឺដើម្បីជាតិ និងប្រជាជន។ យើងលឺពាក្យមហិមាបែបនេះ ក៏លែងគិតអីទៀត ជឿយកតែម្ដង។ អ្នកនយោបាយស្រលាញ់មនុស្សដែលចូលចិត្តនិយាយថា “សុខចិត្តជឿខុស ប្រសើរជាងមិនជឿ”ណាស់ ព្រោះមនុស្សបែបនេះហើយ ដែលត្រូវនឹងបំណងរបស់គេ។

ខ្មែរ ជាជាតិសាសន៍ដែលពូកែជឿ តែមិនពូកែគិត។ គិតបានតែរឿងគ្មានប្រយោជន៍ ប៉ុន្តែដល់ពេលទាក់ទងនឹងសេរីភាពខ្លួនឯង បែរជាមិនហ៊ានគិតទៅវិញ។ អ្នកខ្លះ ស្មានតែខ្លួនឯងឆ្លាតដែលអាចយល់សម្ដីរបស់អ្នកនយោបាយ ហើយតាំងខ្លួនជាអ្នកវិភាគនយោបាយទៀតផង។ ពួកគេ ភ្លេចគិតថា អ្វីដែលអ្នកនយោបាយនិយាយ គឺចង់ឱ្យមនុស្សដូចពួកគេយល់ ហើយយកទៅ បកស្រាយបន្ត។ អ្នកនយោបាយ មិននិយាយអ្វីដែលយើងមិនយល់ទេ ព្រោះវាខាតប្រយោជន៍របស់គេ ហើយគេស្គាល់ប្រភេទមនុស្សដែលគេចង់អូសទាញច្បាស់ណាស់។

នៅមានហេតុផលមួយទៀតដែលគេមិនចង់ឱ្យយើងរៀនចេះដឹងច្រើន គឺយើងរស់នៅដោយខុសពីអ្នកដទៃ។ ខ្ញុំមើលសង្គមដែលខ្ញុំរស់នៅក្នុងផ្លូវអវិជ្ជមានជានិច្ច ព្រោះខ្ញុំដឹងពីរឿងអាក្រក់ និងសកម្មភាពក្លែងក្លាយរបស់មនុស្សក្នុងសង្គមច្រើនពេក។ រឿងល្អដែលខ្ញុំធ្លាប់ជួប មានតិចពេក ហើយមិនសូវសំខាន់ទៀត ហេតុនេះបើគេសួរខ្ញុំ គេនឹងបានចម្លើយអវិជ្ជមានពីខ្ញុំ។

មនុស្សត្រូវការភាពវិជ្ជមាន ដើម្បីជីវិតរស់មានន័យ។ ការស្គាល់អ្វីជាការពិត និងអ្វីជាការបោកប្រាស់ ក៏ជារឿងវិជ្ជមានមួយដែរ។ វាមិនធ្វើឱ្យយើងឆ្កួតនឹងការគិតវិជ្ជមានមែន តែវាធ្វើឱ្យយើងដឹងថា អ្នកណាមានបំណងអ្វីមកលើយើង ហើយនឹងមានរឿងអ្វីកើតឡើងបន្តទៀត។ ការគិតវិជ្ជមាន មិនមែនសម្រាប់ប្រើគ្រប់ពេល និងគ្រប់ទីកន្លែងទេ។ បើយើងរស់នៅក្នុងសង្គមដែលមានរឿងអវិជ្ជមានច្រើន យើងត្រូវមើលវាក្នុងផ្លូវអវិជ្ជមាន ទើបរកឃើញការពិតច្រើនជាងអ្នកដទៃ។ ការគិតវិជ្ជមាន ក្នុងសង្គមអវិជ្ជមាន ជាការដេកស្រមៃដែលនាំយើងឱ្យជាប់អន្ទាក់របស់អ្នកធំប៉ុណ្ណោះ។

ដឹងរឿងច្រើន រស់មិនបានយូរទេ តែបើយើងដឹងច្រើន តែគ្មានអ្នកណាដឹងថាយើងដឹងច្រើន យើងអាចរស់បានយូរ ហើយមិនចាញ់បោកគេទៀតផង។

ខ្ញុំដឹងរឿងអីទាក់ទងនឹងអ្នកនយោបាយ ក៏ខ្ញុំមិនយកមកនិយាយដែរ ព្រោះខ្ញុំចង់រស់។ ខ្ញុំមិនចង់ស្លាប់ដោយសារតែយករឿងគេទៅនិយាយទេ។ ការប្រឆាំងនឹងអ្នកនយោបាយដែលមានអំណាចខ្លាំង ជារឿងគ្មានកំណើត តែបដិសេធមិនទទួលអ្នកនយោបាយមកធ្វើជាមេយើង ឬបដិសេធមនោគមរបស់អ្នកនយោបាយ ជារឿងល្អបំផុតសម្រាប់មនុស្សតូចតាចដូចខ្ញុំ។

ឯកសារមានច្រើនណាស់ ដូច្នេះបើចង់ដឹងបន្ថែម សូមស្រាវជ្រាវដោយខ្លួនឯង។ ខ្ញុំគ្មានបំណងជួយអ្នកណាទេ នៅក្នុងសៀវភៅនេះ ដូច្នេះខ្ញុំគ្មានអ្វីត្រូវប្រាប់បន្តទៀតទេ។

បើចង់ដេកលក់បន្ត កុំរៀនច្រើនពេក។

# ទំព័រចុងក្រោយ

អ្នកទាំងអស់គ្នាអានដល់ចប់ហើយ ដូច្នេះបើមានអ្វីដែលមិនយល់ អាចសួរខ្លួនឯងបាន។ កុំសួរខ្ញុំ ព្រោះការពន្យល់ពីនយោបាយដល់មនុស្សមិនស្គាល់គ្នា មិនមែនជាទម្លាប់របស់ខ្ញុំទេ។ ខ្ញុំរស់នៅដោយប្រយ័ត្នខ្លាំងណាស់ ព្រោះខ្ញុំខ្លាចស្លាប់ដោយសារមាត់។ ចម្ងល់ខ្លាំង អាចរកចម្លើយបាននៅតាមបណ្ណាគារ ឬបណ្ណាល័យ(បើយើងមិនចង់អស់លុយ)។

ខ្ញុំពេញចិត្តនឹងសរសេរពីរឿងនយោបាយ តែមិនមែនជាការវិភាគទេ។ ខ្ញុំសរសេរដោយមិនគិតច្រើនជ្រុល ហើយក៏មិនចំណាយពេលច្រើនពេកទៅលើវាដែរ។ បើយើងមិនមែនជាអ្នកនយោបាយ យើងមិនអាចសរសេរពីនយោបាយឱ្យបានស៊ីជម្រៅទេ ទោះបីយើងរៀននយោបាយរាប់ឆ្នាំក៏ដោយ ព្រោះយើងមិនធ្វើដោយផ្ទាល់។ ខ្ញុំមិនជឿសម្ដីអ្នកដែលប្រាប់ខ្ញុំថា គេយល់ពីនយោបាយទេ បើម្នាក់នោះមិនធ្លាប់ធ្វើនយោបាយ ឬមានទំនាក់ទំនងជិតស្និទ្ធនឹងអ្នកនយោបាយ។ ខ្ញុំជឿពាក្យចេញពីមាត់ផ្ទៃក្នុង ច្រើនជាងអ្នកដែលដេកស្រមៃ។ មានផ្ទៃក្នុងច្រើនណាស់ ដែលគេបង្ហើបប្រាប់យើងពីរឿងនយោបាយ ដើម្បីឱ្យយើងបានដឹងថាមានអ្វីកើតឡើងខ្លះ ហើយអ្វីខ្លះគួរឱ្យចាប់អារម្មណ៍។

ខ្ញុំបញ្ជាក់ម្ដងទៀត ចាប់ពីពេលនេះទៅ ខ្ញុំលែងមានចិត្តជួយអ្នកណាទាំងអស់ ហើយខ្ញុំក៏ប្ដូររបៀបសរសេរខ្លះដែរ ដើម្បីកុំឱ្យគេច្រឡំថាខ្ញុំខ្វល់ពីគេ ឬចង់ធ្វើជាវីរបុរស។ ខ្ញុំសុខចិត្តមិនធ្វើអីសោះ ក៏មិនឱ្យគេមកជេរខ្ញុំ ព្រោះតែចង់ជួយគេដែរ។ មនុស្សភ្លើច្រើនពេក ការជួយ ក្លាយទៅជារឿងបំពានសិទ្ធិរបស់គេទៅវិញ។ បើអ្នកទាំងអស់គ្នាគិតតែបន្តិច នឹងយល់ពីអ្វីដែលខ្ញុំចង់ប្រាប់នេះហើយ។

ជាចុងក្រោយ ខ្ញុំសូមអរគុណអ្នកដែលបានអានសៀវភៅដ៏ខ្លីមួយនេះ។ កុំភ្លេចអានសៀវភៅផ្សេងទៀតផង ព្រោះកុំឱ្យខ្លួនយើងដេកលក់យូរពេក។ ភ្ញាក់ខ្លួនឡើង យើងនឹងមើលឃើញសង្គមដែលយើងរស់នៅក្នុងផ្លូវផ្សេង ហើយចំណុចតូចៗដែលយើងមើលរំលងពីមុន នឹងក្លាយជារឿងល្អរបស់យើងមិនខាន។ បើយើងប្ដូរការគិត យើងនឹងប្ដូរក្រសែភ្នែក។ បើកចិត្តទទួលការពិត ដើម្បីដាស់ចិត្តយើងឱ្យភ្ញាក់ ទាន់អ្នកដទៃ។ មានអ្នកភ្ញាក់ខ្លួនបណ្ដើរៗហើយ យើងក៏មិនគួរដំអក់ទៀតដែរ។

បើចង់អានសៀវភៅផ្សេងទៀតរបស់ខ្ញុំ អាចទាក់ទងតាមផេករបស់ខ្ញុំបាន។ កុំភ័យ ឱ្យតែយកលុយមកឱ្យខ្ញុំ ខ្ញុំខ្វល់ជាមួយគេណាស់ គ្រាន់តែពេលខ្លះខ្ញុំត្រូវប្រើពាក្យអាក្រក់ស្ដាប់ខ្លះដើម្បីឱ្យឆាប់យល់គ្នាប៉ុណ្ណោះ។